ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការខេត្តបាត់ដំបង
សំណុំរឿងព្រហ្មទណ្ឌ
លេខ : ៦៥១ ចុះថ្ងៃទី ០១
ខែ តុលា ឆ្នាំ ២០០៣
សាលក្រមព្រហ្មទណ្ឌ
លេខ : ១២ "ក" ចុះថ្ងៃទី ១៨
ខែ មករា ឆ្នាំ ២០០៦

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តបាត់ដំបង**

បានបើកសវនាការជាសាធារណៈនៅនាទីតុលាការខេត្តបាត់ដំបង នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅ :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ប្រធានតុលាការខេត្តបាត់ដំបង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**ដើម្បីជំនុំជំរះ**

រឿងក្តីព្រហ្មទណ្ឌលេខ ៦៥១ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៣ ដែលមានជនជាប់ចោទ ។

១-ឈ្មោះ រ សអ ភេទស្រី អាយុ ២៤ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីលក់នំ មានទីកន្លែងកំណើតនៅភូមិរតនៈ ឃុំរតនៈ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង មានកំរិតវប្បធម៌ថ្នាក់ទី ០៩ថ្មី កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃនៅភូមិរតនៈ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង មានប្តីឈ្មោះ ជ យថ (រ) មានកូន ០១នាក់ មានឪពុកឈ្មោះ រ ន (ស) មានម្តាយឈ្មោះ ស ន (រ) ទោសពីមុនគ្មាន( ក្រៅឃុំ) ។ ដែលមានមេធាវី ថ្នាក់ គិន ជាអ្នកការពារ ។

២-ឈ្មោះ ខ សអ ភេទស្រី អាយុ ៣៦ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ មានរបររកស៊ីលក់នំ មានទីកន្លែងកំណើតនៅភូមិស្បូវ ឃុំស្បូវ ស្រុកកែប ខេត្តកំពត មានកំរិតវប្បធម៌ថ្នាក់ទី ០៧ថ្មី សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃភូមិរតនៈ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង ប្តីឈ្មោះ ទ វង (រ) មានកូន ០២នាក់ ឪពុកឈ្មោះ ខ ស (រ) ម្តាយឈ្មោះ ឆ ចន (រ) ទោសពីមុនគ្មាន ក្រៅឃុំ ។ ដែលមានមេធាវី ថ៊ុន រិទ្ធី ជាអ្នកការពារ ។

ត្រូវចោទពីបទ បង្ករបួសស្នាមដោយចេតនាឥតអាវុធ និង ជេរប្រមាថ តាមបញ្ញត្តិមាត្រា ៤១ និង ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។ ប្រព្រឹត្តនៅភូមិរតនៈ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៣ ។ វត្ថុរឹងត្រូវឱ្យព្យាបាលចំនួន ១០ថ្ងៃលើកលែងតែមានផលវិបត្តិជាយថាហេតុទៅអនាគត ។



Scanned with CamScanner

តាមវិញ្ញាបនប័ត្រពេទ្យលេខ ១៩៨ វពប.វិ.ប ចុះថ្ងៃទី 0៤ ខែ វិច្ឆិកា ឆ្នាំ ២00៣ របស់មន្ទីរពេទ្យបង្អែកបាត់ដំបង បញ្ជាក់ថា មន្ទីរពេទ្យបានពិនិត្យព្យាបាលអ្នកជម្ងឺឈ្មោះ ខ សអ ដែលចូលមកពីមន្ទីរពេទ្យ កាលពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២00៣ ដោយមូលហេតុរបួសដោយគេវាយ ហើយបានចេញពីមន្ទីរពេទ្យនៅថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២00៣ ។ ការពិនិត្យនៅពេលចូលឃ្លាមឃើញថា ហើមម្រាមដៃស្តាំទី ៤ ទំហំ ២សម ខ ៣សម. របកស្បែកដើមដៃឆ្វេងទំហំ ២សម x 0.៥0សម. របកស្បែកភ្លៅឆ្វេងផ្នែកខាងក្រោយ ២.៥0សម x 0.៣0សម ។ ការសន្និដ្ឋានមុខរបួសនេះជាមុខរបួសត្រូវនឹងវត្ថុរឹងតំរូវការព្យាបាល ១0ថ្ងៃ លើកលែងតែមានផលវិបត្តិជាយថាហេតុទៅអនាគត ។

**ពេលសវនាការ**

-ឈ្មោះ ន សអ ជាជនជាប់ចោទ ជាជនរងគ្រោះ និង ជាដើមបណ្តឹងឆ្លើយថា កាលពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២00៣ ឈ្មោះ ន ន ជាបងស្រីរបស់ខ្លួនបាននិយាយអប់រំណែនាំកូនស្រីរបស់ឈ្មោះ ខ សអ១ បានខឹងនឹងបងរបស់ខ្លួន ហើយបានវាយទៅលើបងស្រីរបស់ខ្លួន ។ ខ្លួនឃើញដូច្នេះបានទៅឃាត់ ពេលនោះឈ្មោះ ខ សអ បែរជាមកវាយលើខ្លួន ប្រវាយនឹងខ្លួនបណ្តាលឱ្យខ្លួនដួលទៅក្នុងភក់ ហើយប្តីរបស់ខ្លួនឈ្មោះ ៩ យ៩ ឃើញខ្លួនដួលបានរត់មកលើកខ្លួនក្រោយកទៅផ្ទះ ។ ឈ្មោះ ខ សអ បានជេរប្រមាថមកលើខ្លួនថា អញ្ជាវាយម៉ែងឱ្យងាប់វាយរលូតកូន ឱ្យកូនងាប់នៅក្នុងពោះ ម៉ែម៉ែងមិនចេះប្រដៅកូន ។ ខ្លួនមិនបានជេរប្រមាថ ឬ វាយទៅវិញទេ គ្រាន់តែប្រតាយទៅវិញទៅមកប៉ុណ្ណោះ ខ្លួនមានសាក្សី ៩ សទ. ៩ សម នៅកន្លែងកើតហេតុបានឃើញហេតុការណ៍ ។ នៅពេលនេះខ្លួនទាមទារសំណងថ្លៃថ្នាំព្យាបាលរបួស និង ជម្ងឺចិត្តជាប្រាក់ចំនួន ១00.000រៀល ពីឈ្មោះនេះ ។

ឈ្មោះ ខ សអ ជាជនជាប់ចោទ ជនរងគ្រោះ និង ជាដើមបណ្តឹងឆ្លើយថា នៅថ្ងៃកើតហេតុនោះ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២00៣ រឿងដើមដំបូងកូនស្រីរបស់ខ្លួនបានប្រាប់ខ្លួនថា គេជេរប្រមាថខ្លួន ខ្លួនមើលទៅឃើញ និង ស្តាប់ឮឈ្មោះ ន សអ កំពុងជេរប្រមាថលើខ្លួនមែន ។ ខ្លួនបានទៅសាកសួរ ស្រាប់តែឈ្មោះនេះវាយដោយដៃមកលើខ្លួន បណ្តាលឱ្យខ្លួនរកកលនឹងដួល ហើយខ្លួនក៏ស្រវាតោងឈ្មោះ ន ន ។ ពេលនោះឈ្មោះ ន សអ និង ឈ្មោះ ៩ យ៩ ជាប្តីឈ្មោះនេះ បានព្រួតគ្នាវាយមកលើខ្លួន ខ្លួនប្រវាយបំរះ រត់ទៅផ្ទះ ។ ឈ្មោះ ន សអ បានជេរប្រមាថនាងខ្ញុំថា មីកញ្ចាស់ អញឱ្យប្តីអញទៅរុកម៉ែងដល់ផ្ទះ ក៏ម៉ែងពុំធ្វើអីក្តប្តីអញបានដែរ ។ នាងខ្ញុំរបួសមុខ ខ្លួនមិនបានជេរ ឬ វាយទៅលើឈ្មោះ ន សអ វិញទេ គ្រាន់តែថា ម្តាយឯងក៏ចាស់ដែរ ។ ខ្លួនរងរបួសហើមជើងបាក់ ម្រាមដៃ ខ្លួនមានសាក្សីដែរ តែឪពុកម្តាយសាក្សីនេះគេខ្លាច មិនឱ្យចូលមកឆ្លើយទេ ។ រឿងនេះខ្លួនសុំទាមទារសំណងថ្លៃព្យាបាល និង ជម្ងឺចិត្តជាប្រាក់ចំនួន ៥0.000បាត ក្នុងនោះជម្ងឺចិត្ត ៥.000បាត. ពីឈ្មោះនេះ ។

ឈ្មោះ ៩ សទ ជាសាក្សីឆ្លើយថា នៅថ្ងៃកើតហេតុនោះ ខ្លួនឮឈ្មោះ ខ សអ ជេរបញ្ឆោរ ឯឈ្មោះ ន ន មិនឮជេរទេ ។ ឈ្មោះ ន សអ ខឹងបានជេរប្រមាថគ្នាទៅវិញទៅមក កើតជាការប្រតាយប្រតប់គ្នា ។ ឈ្មោះ ៩ យ៩ បានរត់ទៅឃាត់ ហើយឈ្មោះនេះនាំឈ្មោះ ន សអ ជាប្រពន្ធមកផ្ទះវិញ ។ ពាក្យជេរប្រមាថនេះ ខ្លួនឮថា មីចោរកាចុយ មីអាយះ ជេរទៅមក ។

ឈ្មោះ ៩ សម ជាសាក្សីឆ្លើយថា នៅថ្ងៃកើតហាតុនោះ ខ្លួននៅចំងាយប្រហែល ៧ម ពីកន្លែងកើតហេតុបានឃើញឈ្មោះ ន ន ជាបងស្រីរបស់ឈ្មោះ ន សអ និយាយណែនាំកូនស្រីរបស់ឈ្មោះ ខ សអ ហើយឈ្មោះ ខ សអ ខឹងវាយទៅលើឈ្មោះ ន ន ។ ឈ្មោះ ន សអ រត់ទៅឃាត់ ក៏កើតជាការប្រវាយប្រតប់គ្នា ។ ឈ្មោះ ន សអ ដួល ប្តីរបស់ឈ្មោះនេះទៅលើកនាំយកមកផ្ទះ ។ អ្នកទាំងពីរជេរគ្នា តែពាក្យជេរទាំងនោះ ខ្លួនភ្លេចអស់ហើយ ។



Scanned with CamScanner

តាមការអានចម្លើយឈ្មោះ រ ន បញ្ជាក់ថា នៅថ្ងៃកើតហេតុ រឿងដំបូងខ្លួនឮកូនស្រីរបស់ឈ្មោះ ខ អ និយាយប្រើពាក្យមិនសមរម្យ ខ្លួនបាននិយាយណែនាំស្រាប់តែឈ្មោះ ខ សអ ស្ទុះមកវាយលើខ្លួនដោយដៃ ។ ប្អូនរបស់ខ្លួនបានឃើញ ហើយរត់មកទាញខ្លួនឱ្យទៅផ្ទះ ស្រាប់តែឈ្មោះ ខ សអ មកវាយបោចសក់ប្អូនស្រីរបស់ខ្លួនប្រតាយគ្នា ប្អូនរបស់ខ្លួនដួលទៅលើភក់នៅមុខផ្ទះ ហើយឈ្មោះ ៩ យទ ជាប្តីបានលើកគ្រាប្រពន្ធឈ្មោះ រ សអ ទៅផ្ទះ ។ ឈ្មោះ ខ សអ ស្រែកជេរថា អាឆ្កែ មីកូនងាប់ក្នុងពោះ មីកើតកូនមិនគ្រប់ខែ អស់រយៈពេលប្រហែលកន្លះម៉ោងទើបឈប់ ។

តាមការអានចម្លើយឈ្មោះ ន គរម ជាសាក្សីឆ្លើយប្រហែល នឹងឈ្មោះ រ ន ខាងលើដែរ តែត្រង់ពាក្យជេរប្រមាថ បញ្ជាក់ថាឈ្មោះ ខ សអ ជេរប្រមាថថា អាឆ្កែ កណ្តុយម៉ែវា កូនមីចោរកាចុយ មីកំផើម មីកើតកូនមិនគ្រប់ខែ អញវាយង៉ែងឱ្យធ្លាយកូន និង បញ្ជាក់ថា មិនឃើញឈ្មោះ រ សអ ជេរប្រមាថទៅវិញទេ ។

តាមការអានចម្លើយឈ្មោះ ទ ឆរ ជាសាក្សីបានឆ្លើយបញ្ជាក់ប្រហាក់ប្រហែល និង ចម្លើយឈ្មោះ ន គរម ខាងលើដែរ តែពាក្យជេរប្រមាថឈ្មោះ ទ ឆរ បញ្ជាក់ថា ឈ្មោះ ខ សអ ប្រើពាក្យ អាចុយម្រាយ មីកំផើម អញវាយង៉ែងឱ្យចេញកូន កណ្តុយម៉ែវា ។

តាមការអានចម្លើយឈ្មោះ ត សម ជាសាក្សីឆ្លើយថា នៅថ្ងៃមិនចាំ ជាថ្ងៃកើតហេតុ ខែ កញ្ញា ឆ្នាំ ២០០៣ វេលាម៉ោងប្រហែល ៧ និង ១៥នាទី ជិតយប់ខ្លួន ខ្លួនបានឮ២នាក់ប្រកែកគ្នា រវាងឈ្មោះ ទ និង ឈ្មោះ អ ខ្លួនទៅមើលបានឃើញអ្នកទាំងពីរប្រកែកគ្នា ដោយមូលហេតុរឿងកូនរបស់ឈ្មោះ អ ហើយរឿងនេះ ក៏ស្ងាត់ឈប់ទៅ ។ លុះក្រោយមកបន្តិច ស្រាប់តែឮសូរមាត់ប្រកែកគ្នាទៀត ខ្លួនទៅមើលឃើញអ្នកគ្រូពៅប្រកែកគ្នានឹងឈ្មោះ អ រហូតដល់មានការប្រតាយគ្នា ហើយឈ្មោះ រ បានវាយទៅលើឈ្មោះ អ ផ្អើលដល់អ្នកជិតខាងចូលទៅឃាត់ទើបឈប់ ។ ក្រោយពេលវាយមានជេរគ្នាផង ។

តាមការអានចម្លើយឈ្មោះ ម ម ជាសាក្សីបញ្ជាក់ថា នៅថ្ងៃមិនចាំ ខែ កញ្ញា ឆ្នាំ ២០០៣ វេលាម៉ោង

ប្រហែល ០៧យប់ ខ្លួនឮមាត់ប្រកែកគ្នារវាងឈ្មោះ ព ហៅអ្នកគ្រូ ន និង ឈ្មោះ អ អំពីរឿងកូន ហើយឈ្មោះ ព បានវាយទៅលើឈ្មោះ អ បណ្តាលឱ្យមានការប្រតាយគ្នា ។ ពេលនោះឈ្មោះ ត និង ប្តីបានទៅវាយលើឈ្មោះ អ ហើយត្រូវចាស់ៗ មកជួយឃាត់ ចំណែកខ្លួនត្រឡប់មកផ្ទះវិញ ។

<u>**តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការបញ្ជាក់ថា**</u> :

-មានភស្តុតាង និង ពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ រ សអ និង ខ សអ ពីបទបង្ករបួសដោយចេតនាឥតអាវុធ និង ជេរប្រមាថ ប្រព្រឹត្តនៅភូមិរតនៈ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៣ ។

បទល្មើសព្រហ្មទណ្ឌមានចែង និង ផ្តន្ទាទោសតាមមាត្រា ៤១ និង ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-តម្កល់បទចោទ និង សុំតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពី ០៤ខែ ដល់ ១២ខែ ពីបទបង្ករបួសស្នាមដោយចេតនាឥតអាវុធ និង ពី ០៤ខែ ដល់ ១២ ខែ ពីបទជេរប្រមាថក្នុងជនជាប់ចោទម្នាក់ៗ ។

<u>**តាមសេចក្តីសន្និដ្ឋានរបស់មេធាវី**</u> **ទ្រាត់ គិន** ការពារក្តីឱ្យជនជាប់ចោទឈ្មោះ រ សអ បញ្ជាក់ថា :

-របាយការណ៍របស់នគរបាលស្រុកបាត់ដំបង បានសន្និដ្ឋានដាក់កំហុសលើកូនក្តីរបស់ខ្លួនឈ្មោះ រ សអ

ថា ជាអ្នកបង្កហេតុឱ្យមានរបួស ពុំមានលក្ខណៈត្រឹមត្រូវទេ ដោយហេតុ កំណត់ហេតុដែលរបាយការណ៍នេះយោងបានបញ្ជាក់ថា ឈ្មោះ ខ សរអ និង ឈ្មោះ រ សរអ បានបង្ករបួសដូចគ្នា ។

-សាក្សីឈ្មោះ ៩ សទ និង ៩ សម របស់កូនក្តីខ្លួននៅកន្លែងកើតហេតុ បានឃើញនូវហេតុការណ៍ដែលកូនក្តីរបស់ខ្លួនបានរងគ្រោះ ។

-របួសរបស់ឈ្មោះ ខ សរអ មិនមែនបង្កដោយកូនក្តីរបស់ខ្លួនទេ ។

-ខ្លួនសុំបដិសេធរបាយការណ៍របស់នគរបាលស្រុក សុំបដិសេធចម្លើយសាក្សីរបស់ឈ្មោះ ខ សរអ ចំនួន ០២នាក់ ដែលឆ្លើយខុសពីការពិត, សុំឱ្យកូនក្តីរបស់ខ្លួន រួចខ្លួនពីបទចោទ, សុំតុលាការសំរេចពីជម្ងឺចិត្តឱ្យកូនក្តីរបស់ខ្លួនទៅតាមសំណូមពរ និង សុំតុលាការផ្តន្ទាទោសលើឈ្មោះ ខ សរអ ទៅតាមច្បាប់ ។

**តាមសេចក្តីសន្និដ្ឋានរបស់មេធាវី ម៉ុន រិទ្ធី** ការពារក្តីឱ្យជនជាប់ចោទឈ្មោះ ខ សរអ បញ្ជាក់ថា :

-កូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តអំពើបង្ករបួសជាមុនទេ, កូនក្តីខ្លួនជាអ្នករងគ្រោះពិតប្រាកដ ពីអំពើបង្ករបួសរបស់ឈ្មោះ រ សរអ, រ ន, និង ប្តីរបស់ឈ្មោះ រ សរអ ។

-ចម្លើយសាក្សីឈ្មោះ ៩ សទ, ៩ សម ជាចម្លើយលំអៀង ដោយហេតុសាក្សីទាំង ០២នាក់នេះជាសាច់ញាតិរបស់ឈ្មោះ រ សរអ ។

-ក្រោយពេលកើតហេតុនគរបាលបានពិនិត្យ និង ធ្វើគំនូសស្លាកស្នាមរបួស ហើយបានទៅពិនិត្យព្យាបាលនៅមន្ទីរពេទ្យ មានវិញ្ញាបនប័ត្របញ្ជាក់ស្របគ្នា ឯឈ្មោះ រ សរអ ពុំបានធ្វើការពិនិត្យ ធ្វើគំនូសស្លាកស្នាមពិនិត្យដោយប៉ូលីសទេ ស្រាប់តែចេញជាវិញ្ញាបនប័ត្រតែម្តង ។

-សំណូមពរសុំលើកលែងកូនក្តីរបស់ខ្លួនពីបទចោទ, សុំតុលាការសំរេចលើសំណងព្យាបាល និង ជម្ងឺចិត្ត ៥០.០០០បាត តាមសំណូមពរកូនក្តីរបស់ខ្លួន ។

**តាមសំដីចុងក្រោយរបស់ជនជាប់ចោទបញ្ជាក់ថា :**

-ឈ្មោះ រ សរអ សុំតុលាការឱ្យខ្លួនរួចពីបទចោទ ។

-ឈ្មោះ ខ សរអ សុំតុលាការឱ្យខ្លួនរួចពីបទចោទ និង ទារជម្ងឺចិត្ត ។

-បានស្តាប់ចម្លើយជនជាប់ចោទដែលជាជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណីទាំងពីរនាក់

-បានស្តាប់ចម្លើយឱ្យការណ៍របស់សាក្សី, សាក្សីពន្លឺ

-បានស្តាប់ការសួរដេញដោល ចោទឆ្លើយតទល់

-បានពិនិត្យកំណត់ហេតុ ឯកសារភស្តុតាងនានា

-បានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ទោសរបស់តំណាងអយ្យការ

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-បានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-បានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការខេត្តបាត់ដំបងយល់ឃើញថា

-ពិតជាកើតមាននូវអំពើជេរប្រមាថ និង បង្ករបួសស្នាមដោយចេតនាឥតអាវុធ នៅភូមិរតនៈ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៣ ប្រាកដមែន ។



Scanned with CamScanner

-អំពើជេរប្រមាថ និង បង្ករបួសស្នាមដោយចេតនាឥតអាវុធដែលកើតមាននៅទីកន្លែង និង ពេលវេលាដូចខាងលើពិតជាប្រព្រឹត្តឡើងដោយឈ្មោះ រ សអ និង ឈ្មោះ ខ សអ ដែលបានជេរប្រមាថគ្នា និង វាយតប់គ្នាឥតអាវុធទៅវិញទៅមកប្រាកដមែន ។

-អំពើដែលជនជាប់ចោទទាំងពីរនាក់បានប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចខាងលើនេះមានធាតុផ្សំគ្រប់គ្រាន់ជាបទជេរប្រមាថ និង បទបង្ករបួសស្នាមដោយចេតនាឥតអាវុធ ដូចមានបញ្ញត្តិក្នុងមាត្រា ៦៣ និង មាត្រា ៤១ ត្រង់វាក្យខណ្ឌ ៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ជនជាប់ចោទទាំងពីរនាក់ជាសមត្ថជន មានស្មារតីជានាល្អ គាត់បានប្រព្រឹត្តអំពើដោយចេតនា ជេរប្រមាថសំដៅទៅលើគ្នាទៅវិញទៅមក នូវពាក្យអាសអាភាស. ពាក្យអសុរសយ៉ាងច្រើនដូចជាពាក្យជេរថា មីចោរកណ្តួយអាយះ មីចោរគេចុយ មីកំផើម មីកើតកូនមិនគ្រប់ខែ ឱ្យម៉ែងងាប់តែហោងជាដើម ទន្ទឹមនឹងជេរប្រមាថ ជនជាប់ចោទទាំងពីរនាក់ ក៏បានវាយតប់គ្នាទៅវិញទៅមកដោយដៃទទេ ខ្វាចសាច់គ្នា ចាប់បោចសក់គ្នាទៅវិញទៅមក បណ្តាលឱ្យមានស្នាកស្នាមរបួសស្រាល១រៀងខ្លួន ។

## យល់ឃើញថា

មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទទាំងពីរនាក់ពីបទជេរប្រមាថ និង បទបង្ករបួសស្នាមប្រព្រឹត្តនៅទីកន្លែង និង ពេលវេលាដូចការចោទប្រកាន់របស់អយ្យការប្រាកដមែន ។

**ភស្តុតាងដាក់បន្ទុកមាន :**

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ រ សអ បានឆ្លើយបញ្ជាក់យ៉ាងច្បាស់ថា : ខ្លួនត្រូវបានឈ្មោះ ខ សអ វាយបោចសក់ និង ច្រានខ្លួនដួលកប់ភក់ និង បានជេរប្រមាថខ្លួន និង ប្តីរបស់ខ្លួនអស់រយៈពេលប្រហែលកន្លះម៉ោងទើបឈប់ ចម្លើយនេះវាស៊ីសង្វាក់គ្នាទៅនឹងចម្លើយឱ្យការណ៍របស់សាក្សីឈ្មោះ ន គរម. ទ ឆរ. ៩ សរ. ៩ សម ។

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ ខ សអ បានឆ្លើយឱ្យការណ៍ថា ខ្លួនត្រូវឈ្មោះ រ សអ. ឈ្មោះ រ ន និង ឈ្មោះ ៩ យទ ព្រួតគ្នាវាយខ្លួន និង ជេរប្រមាថខ្លួន ចម្លើយនេះវាស៊ីសង្វាក់គ្នាទៅនឹងចម្លើយឱ្យការណ៍របស់សាក្សីឈ្មោះ ម ម. ឈ្មោះ ត សម និង របាយការណ៍ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ របស់ នគរបាលស្រុកបាត់ដំបង ។

-ចម្លើយឱ្យការណ៍របស់សាក្សីឈ្មោះ ន គរម. ទ ឆរ. ៩ សរ. ៩ សម. ម ម និងឈ្មោះ ត សម ។

-កំណត់ហេតុ ឯកសារភស្តុតាងនានាធ្វើឡើងដោយនគរបាលយុត្តិធម៌ ។

-វិញ្ញាបនប័ត្រពេទ្យលេខ : ១៩៨ មពប.វិប ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០៣ និង លេខ : ២១៨ មពប.វិប ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ចេញដោយមន្ទីរពេទ្យបង្អែកបាត់ដំបង ។

## យល់ឃើញថា

ជនជាប់ចោទឈ្មោះ ខ សអ ប្រព្រឹត្តអំពើបង្ករបួសដោយចេតនាឥតអាវុធ និង ជេរប្រមាថទៅលើឈ្មោះ រ សអ ធ្ងន់ជាង ច្រើនជាង ម្យ៉ាងទៀតឈ្មោះ រ សអ កំពុងមានគភ៌ជិតគ្រប់ខែផង ជាហេតុតុលាការយកមកពិចារណាជាស្ថានទម្ងន់ទោសក្នុងការសម្រេចពីទណ្ឌកម្ម ។

ឈ្មោះ រ សអ បានបង្ករបួស និង ជេរទៅលើឈ្មោះ ខ សអ មានលក្ខណៈស្រាលជាហេតុតុលាការយក



Scanned with CamScanner

មកពិចារណាជាស្ថានសម្រាលបាន ។

ជនជាប់ចោទទាំង ០២នាក់ មានលំនៅដ្ឋាន មានមុខរបរ ក្រុមគ្រួសារត្រឹមត្រូវ ហើយគាត់ជាប់ចោទពីបទមជ្ឈិមតូចតាច ជាហេតុអាចតុលាការឱ្យពួកគាត់ទទួលទោសព្យួរបាន ។

ឈ្មោះ ៖ **សអ** បានប្តឹងទារប្រាក់សំណងថ្លៃចំណាយក្នុងការព្យាបាលរបួស និង ជម្ងឺចិត្តពីឈ្មោះ ខ **សអ** ចំនួន ១០០.០០០រៀល ធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

ឈ្មោះ ខ **សអ** បានប្តឹងទារប្រាក់សំណងថ្លៃចំណាយក្នុងការព្យាបាលរបួសចំនួន ៤៥.០០០បាត និង ជម្ងឺចិត្តចំនួន ៥.០០០បាត ពីឈ្មោះ ៖ **សអ** ធ្វើឡើងបានត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ តែមានចំនួនច្រើនណាស់ម្យ៉ាងទៀតឈ្មោះ ខ **សអ** បានប្រព្រឹត្តអំពើទៅលើឈ្មោះ ៖ **សអ** ធ្ងន់ជាង ត្រូវទទួលខុសត្រូវច្រើនជាង ។

ឈ្មោះ ខ **សអ** មានរបួសបាក់ម្រាមដៃមួយ ដោយគាត់មិនដឹងថាបណ្តាលមកពីអ្វី ឬ មកពីអ្នកណាឡើយមិនត្រូវឱ្យឈ្មោះ ៖ **សអ** ទទួលខុសត្រូវឡើយ ។

## ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី

១-ក.ផ្តន្ទាទោសឈ្មោះ ៖ **សអ** ដាក់ពន្ធនាគារកំណត់ :

-០១ខែគត់ពីបទជេរប្រមាថ ។

-០២ខែគត់ពីបទបង្ករបួសស្នាមដោយចេតនាឥតអាវុធ ។ +ព្យួរ

ទណ្ឌកម្មសរុបកំណត់ ០៣ខែ តែទោសនេះឱ្យឈ្មោះ ៖ **សអ** ទទួលទោសព្យួរដោយកំណត់រយៈពេលសាកល្បងកំណត់ ០៥ឆ្នាំ គិតចាប់ពីក្រោយពេលប្រកាសសាលក្រមនេះតទៅ ។

ខ.ផ្តន្ទាទោសឈ្មោះ ខ **សអ** ដាក់ពន្ធនាគារកំណត់ :

-០៣ខែគត់ពីបទជេរប្រមាថ ។

-០២ខែគត់ពីបទបង្ករបួសស្នាមដោយចេតនាឥតអាវុធ ។

ទណ្ឌកម្មសរុបកំណត់ ០៥ខែគត់ តែទោសនេះឱ្យឈ្មោះ ខ **សអ** ទទួលទោសព្យួរដោយកំណត់រយៈពេលសាកល្បងកំណត់ ០៥ឆ្នាំ គិតចាប់ពីក្រោយពេលប្រកាសសាលក្រមនេះតទៅ ។

ពីបទជេរប្រមាថ និង បទបង្ករបួសស្នាមដោយចេតនាឥតអាវុធ ប្រព្រឹត្តនៅភូមិរតនៈ ឃុំរតនៈ ស្រុកបាត់ដំបង ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៣ ។

បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និង ការផ្តន្ទាទោស តាមបញ្ញត្តិក្នុងមាត្រា ៤១ ត្រង់វាក្យខណ្ឌ ៣ មាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

តាមបទបញ្ញត្តិមាត្រា ៨ ច្បាប់ស្តីពីស្ថានទម្ងន់ទោស នៃបទឧក្រិដ្ឋ ។

២-ក-ឱ្យឈ្មោះ ៖ **សអ** សងសំណងថ្លៃចំណាយក្នុងការព្យាបាលរបួស និង ជម្ងឺចិត្តឱ្យទៅឈ្មោះ ខ **សអ** ចំនួន ១០០.០០០រៀល"ដប់ម៉ឺនរៀលគត់" ។ ឈ្មោះ ខ **សអ** ទារលើសពីនេះបដិសេធចោល ។

ខ-ឱ្យឈ្មោះ ខ **សអ** សងសំណងថ្លៃចំណាយក្នុងការព្យាបាលរបួស និង ជម្ងឺចិត្តឱ្យទៅឈ្មោះ ៖ **សអ** ចំនួន ១០០.០០០រៀល"ដប់ម៉ឺនរៀលគត់" ។

ក្នុងករណីឈ្មោះ ៖ **សអ** និង ឈ្មោះ ខ **សអ** គ្មានប្រាក់សងធនទណ្ឌគ្រប់ចំនួនត្រូវដាក់គុកបង្ខំដល់រូបកាយក្នុងម្នាក់ៗកំណត់យ៉ាងយូរបំផុតត្រឹម ២០០ថ្ងៃ ដើម្បីបង្ខំទារធនទណ្ឌ ។



Scanned with CamScanner

តាមបទបញ្ញត្តិមាត្រា ៧ និង មាត្រា ១០ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយ ក្នុងរឿងព្រហ្មទណ្ឌ
ដែលបានប្រកាសឱ្យប្រើតាមក្រឹត្យលេខ ១៨ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

៣-សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និង ជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ
 ៖ សអ និង ឈ្មោះ ខ សអ ។

បើកផ្លូវប្តឹងឧទ្ធរណ៍កំណត់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

**ក្រឡាបញ្ជីសវនាការ** [redacted]

**ចៅក្រមជំនុំជំរះ** [redacted]

---

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ព្រាស់បង្គាប់មកអ្នកអនុវត្តសាលក្រមឱ្យសំរេចតាម
សាលក្រមនេះ និង ឱ្យអាជ្ញាធរគ្រប់តំណែង គ្រប់ជាន់ថ្នាក់ជួយអនុវត្ត បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

*បាត់ដំបង, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៦*
**ជ.ក្រឡាបញ្ជីសវនាការ**
[redacted]

**បានឃើញ**
*បាត់ដំបង, ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៦*
**ប្រធានតុលាការខេត្ត**
[redacted]

Scanned with CamScanner